**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ១២៦ អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពី
## ការផ្ទេរដីទំហំ ៣៥០ (បីរយហាសិប) ហិកតា ចេញពីដីសម្បទានសេដ្ឋកិច្ច របស់ក្រុមហ៊ុន អាន ម៉ាឌី គ្រុប ស្ថិតនៅក្នុងឃុំត្រស់ និងឃុំគគីរ ស្រុករមាសហែក ខេត្តស្វាយរៀង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីព្រៃឈើ

Downloaded from http://www.khmerlaws.com

- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ ២០០៥ ស្តីពី សម្បទានដីសេដ្ឋកិច្ច
- បានឃើញអនុក្រឹត្យលេខ ១៥៤ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការផ្ទេរសិទ្ធិគ្រប់គ្រងចំការកៅស៊ូពាមជាំង
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.-**

ត្រូវបានផ្ទេរដីទំហំ ៣៥០ (បីរយហាសិប) ហិកតា ចេញពីទំហំដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន អានម៉ាឌីគ្រុប ស្ថិតនៅក្នុងឃុំត្រស់ និងឃុំគគីរ ស្រុករមាសហែក ខេត្តស្វាយរៀង ដែលកំណត់ដោយបណ្តាចំណុចគោល ដែលមាននិយាមកានៃប្រពន្ធ័កូអ័រដោណេ UTM, Zone 48 N , Datum Indian 1960 : ពីចំណុច ១ ដល់ចំណុច៦ និងពីចំណុច ៧ ដល់ចំណុច១០ : ១ (៥៩២៩៤៥. ១២៧៤៣៧៤), ២ (៥៩២៤៥៥. ១២៧៤៤៥០), ៣ (៥៩១៩៦៧. ១២៧៤២៥២) , ៤ (៥៩០៦១០. ១២៧៣៤២៥), ៥ (៥៩០០៨០. ១២៧២៩៧០), ៦ (៥៩០១៤២. ១២៧១៣៧២), ៧ (៥៩៤៥៨៨. ១២៦៩៤៩៥), ៨ (៥៩៥០៥០.១២៦៩១៣៥), ៩ (៥៩៥៤៩៣. ១២៦៩៣១០), ១០ (៥៩៥០២០. ១២៧០២៤៦) ដូចមានផែនទីភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ២.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ដីរដ្ឋជូនអាជ្ញាធរកាន់កាប់ដីរដ្ឋខេត្តស្វាយរៀង ដើម្បីចុះបញ្ជីជាដីឯកជនរបស់រដ្ឋទំហំ ៣៥០ (បីរយហាសិប) ហិកតា ដូចមានចែងក្នុងមាត្រា១នៃអនុក្រឹត្យនេះ សម្រាប់គោលដៅសម្បទានដីសង្គមកិច្ច តាមនីតិវិធីច្បាប់ជាធរមាន ។

**មាត្រា ៣.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី

Downloaded from http://www.khmerlaws.com

រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តស្វាយរៀង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

***កន្លែងទទួល :***

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- ក្រុមហ៊ុន អាន ម៉ាឌី គ្រុប
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

Downloaded from http://www.khmerlaws.com




តារាងនិយាមការ

Projection Indian 1960 UTM zone 48N

| Points_ID | Easting (m) | Northing (m) |
|---|---|---|
| 1 | 592945 | 1274374 |
| 2 | 592455 | 1274450 |
| 3 | 591967 | 1274252 |
| 4 | 590610 | 1273425 |
| 5 | 590080 | 1272970 |
| 6 | 590142 | 1271372 |
| 7 | 594588 | 1269495 |
| 8 | 595050 | 1269135 |
| 9 | 595493 | 1269310 |
| 10 | 595020 | 1270246 |

Downloaded from http://www.khmerlaws.com